# ព្រឹត្តិបត្រព័ត៌មាន

មូលនិធិគាំទ្រការបណ្តុះបណ្តាលសុខភាពសិក្សា និងការលើកកម្ពស់អេកូសុខភាព

Supported by THE NIPPON FOUNDATION

លេខ ១ | ថ្ងៃអង្គារ ១៥កើត ខែផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹង ថ្ងៃទី៣ ខែមីនា ឆ្នាំ២០២៦

## តើអង្គការ STEP ជាអ្វី ?




**មូលនិធិគាំទ្រការបណ្តុះបណ្តាលសុខភាពសិក្សា និងការលើកកម្ពស់អេកូសុខភាព** គឺជាអង្គការអន្តរជាតិ ដែលមានទីស្នាក់ការកណ្តាលស្ថិតនៅប្រទេសជប៉ុន។ យើងហៅអង្គការនេះថា NGO STEP ដែលយកអក្សរកាត់ពីឈ្មោះពេញរបស់អង្គការ។ បេសកកម្មរបស់អង្គការ STEP គឺដើម្បីផ្សព្វផ្សាយការដាក់បញ្ចូលកម្មវិធីសុខភាពសិក្សា និងលើកកម្ពស់សុខភាពកុមារនៅប្រទេសកម្ពុជា ។ ជាពិសេស អង្គការ STEP នឹងលើកកម្ពស់គម្រោងសុខភាពសិក្សាតាមវិធីសាស្ត្រអប់រំ ដើម្បីធ្វើឱ្យការអប់រំសុខភាពក្លាយជាមុខវិជ្ជាសំខាន់ក្នុងម៉ោងសិក្សាជាប្រចាំថ្ងៃ។ យើងបានអនុវត្តគម្រោងអភិវឌ្ឍន៍សុខភាពសិក្សាសម្រាប់កុមារកម្ពុជា (SHCC) តាមរយៈសាកលវិទ្យាល័យ តូក្យូ ហ្គាគឺហ្គេ ហើយនឹងបន្តអនុវត្តគម្រោងនេះនៅដំណាក់កាលទី ២ជាបន្តទៀត។

## ចំណាប់អារម្មណ៍ ប្រធានអង្គការ



ខ្ញុំបាទឈ្មោះ អាសាគីវ៉ា តាកាស៊ី ជាប្រធានអង្គការ មូលនិធិគាំទ្រការបណ្តុះបណ្តាលសុខភាពសិក្សា និងការលើកកម្ពស់អេកូសុខភាព(STEP)។ ខ្ញុំជឿជាក់ថា ការលើកកម្ពស់សង្គមកម្ពុជា តម្រូវឱ្យមានវិធីសាស្ត្រដែលមិនមែនពីលើចុះក្រោមសុទ្ធសាទ (top-down) ឬពីក្រោមឡើងលើសុទ្ធសាទ(bottom-up)ទេ ប៉ុន្តែជាវិធីសាស្ត្ររួមផ្សំរវាងពាក់កណ្តាលឡើងលើ(middle-up) និងពាក់កណ្តាលចុះក្រោម (middle-down)។ ក្នុងវិស័យអប់រំសុខភាពសិក្សា គ្រឹះស្ថានបណ្តុះបណ្តាលគ្រូអាចបម្រើជាស្ថាប័នស្នូល ដើម្បីស្នើសុំការធ្វើគោលនយោបាយអប់រំសុខភាពសិក្សា និងការបណ្តុះបណ្តាលគ្រូទៅកាន់រដ្ឋាភិបាល ស្របពេលជាមួយគ្នានេះដែរ ក៏បញ្ជូនគ្រូដែលបានបណ្តុះបណ្តាលឱ្យទៅតាមសាលាមូលដ្ឋាន។ តាមរយៈដំណើរការនេះ សុខភាពកុមារនិងសហគមន៍ទូទាំងប្រទេសអាចប្រសើរឡើង។ ខ្ញុំជឿជាក់ថា ការពង្រឹង «ស្រទាប់កណ្តាល» (middle layer) នេះ គឺជាគន្លឹះសំខាន់ក្នុងការកសាងប្រទេសជាតិ សង្គម និងប្រជាជនកម្ពុជាឲ្យមានសុខភាពល្អប្រសើរជាងមុន។

**សាស្ត្រាចារ្យបណ្ឌិត អាសាគីវ៉ា តាកាស៊ី**
**ប្រធានអង្គការ មូលនិធិគាំទ្រការបណ្តុះបណ្តាលសុខភាពសិក្សា និងការលើកកម្ពស់អេកូសុខភាព(STEP)**

## អំពីអង្គការ STEP

NGO STEP បានគាំទ្រដោយការិយាល័យ (សាកលវិទ្យាល័យ តូក្យូ ហ្គាគឺហ្គេ) និងការិយាល័យនៅប្រទេសកម្ពុជា ក្រោមកិច្ចសហការពីសាស្ត្រាចារ្យមកពីសាកលវិទ្យាល័យផ្សេងៗ ដែលមានចំណេះដឹង និងជំនាញពិសេស។ គម្រោងសំខាន់របស់យើងគឺ គម្រោង SHCC ដែលទទួលបានការគាំទ្រពីមូលនិធិ នីបប៉ុន (The Nippon Foundation)។



## ១ ការអភិវឌ្ឍន៍សៀវភៅសិក្សាគោលសុខភាពសិក្សាសម្រាប់វិទ្យាស្ថានគរុកោសល្យ (TEC)



យើងកំពុងអភិវឌ្ឍសៀវភៅសិក្សាគោលសុខភាពសិក្សា ដែលរៀបចំឡើងដើម្បីជួយគរុនិស្សិតនៅវិទ្យាស្ថានគរុកោសល្យ ឱ្យទទួលបាននូវចំណេះដឹង និងជំនាញចាំបាច់សម្រាប់បង្រៀនមុខវិជ្ជាសុខភាពសិក្សាដល់កុមារប្រកបដោយប្រសិទ្ធភាព។ សៀវភៅសិក្សាគោលនេះមិនត្រឹមតែ ផ្តល់ចំណេះដឹងជាក់ស្តែងសម្រាប់បង្រៀនកុមារប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ខ្លឹមសារទូលំទូលាយ ដែលអនុញ្ញាតឱ្យគរុនិស្សិតសិក្សាអំពីសុខភាពសិក្សាជាវិស័យសិក្សាវេជ្ជសាស្រ្តផងដែរ។

## ២ ការណែនាំកម្មវិធីកម្មសិក្សាគរុកោសល្យសម្រាប់ការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតបឋមសិក្សា នៅវិទ្យាស្ថានគរុកោសល្យ



នៅតាមសាលាបឋមសិក្សានៅប្រទេសកម្ពុជា មុខវិជ្ជាសុខភាពសិក្សា ទើបតែត្រូវបានដាក់បញ្ចូលជាមុខវិជ្ជាថ្មី ហើយគ្រូបន្ទុកថ្នាក់ជាអ្នកបង្រៀនដោយផ្ទាល់។ យើងកំពុងខិតខំបញ្ចូលមុខវិជ្ជាសុខភាពសិក្សា ទៅក្នុងកម្មសិក្សាគរុកោសល្យ ដើម្បីធានាឱ្យបានថាគរុនិស្សិតកម្រិតបឋមសិក្សាដែលបញ្ចប់ការសិក្សានៅវិទ្យាស្ថានគរុកោសល្យ អាចបង្រៀនមុខវិជ្ជាសុខភាពសិក្សាបានយ៉ាងមានប្រសិទ្ធភាពក្នុងបរិបទសាលាពិតប្រាកដ។

## ៣ ការបង្កើតមុខវិជ្ជាឯកទេសសុខភាពសិក្សាសម្រាប់ការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតមធ្យមសិក្សាបឋមភូមិ នៅវិទ្យាស្ថានគរុកោសល្យ



អង្គការ STEP មានគោលបំណងបង្កើតមុខវិជ្ជាឯកទេសសុខភាពសិក្សាដំបូងបង្អស់នៅប្រទេសកម្ពុជា ក្នុងកម្មវិធីអប់រំកម្រិតមធ្យមសិក្សាបឋមភូមិ។ ក្រៅពីការអភិវឌ្ឍកម្មវិធីសិក្សាលម្អិត សៀវភៅសិក្សាគោល និងសម្ភារៈឧបទេសដែលចាំបាច់សម្រាប់ទទួលបានចំណេះដឹងឯកទេស យើងនឹងផ្តល់ជូនគរុនិស្សិតនូវការណែនាំជាក់ស្តែងដូចជា ការគ្រប់គ្រងបន្ទប់សុខភាពសិក្សា តាមរយៈគ្រូឧទ្ទេសសុខភាពសិក្សា។

## ៤ ការបណ្តុះបណ្តាលគ្រូឧទ្ទេសសុខភាពសិក្សា



នៅប្រទេសកម្ពុជា យើងបណ្តុះបណ្តាលគ្រូឧទ្ទេសសុខភាពសិក្សា នៅវិទ្យាស្ថានគរុកោសល្យ ដែលទទួលបន្ទុកបង្រៀនមុខវិជ្ជាសុខភាពសិក្សា។ យើងធ្វើវគ្គបណ្តុះបណ្តាលសុខភាពសិក្សាជាប្រចាំ ដែលគ្របដណ្តប់លើប្រធានបទដូចជា មាតិកានៃសៀវភៅសិក្សាគោលសុខភាពសិក្សា វិធីសាស្រ្តបង្រៀនការអប់រំសុខភាព និងការគ្រប់គ្រងបន្ទប់សុខភាពសិក្សា។ លើសពីនេះទៀត យើងក៏រៀបចំអំពីការសិក្សាស្រាវជ្រាវមេរៀន ដើម្បីលើកស្ទួយគុណភាពការបង្រៀនផងដែរ។

## ចំណាប់អារម្មណ៍ នាយកប្រចាំប្រទេស



STEP គឺជាអង្គការទើបតែបង្កើតថ្មី ប៉ុន្តែសមាជិកមិនថ្មីទេ។ ខ្ញុំជឿជាក់ថា យើងនៅតែអាចបន្តបង្ហាញភាពសហការល្អក្នុងក្រុមការងារដូចមុនបានដដែល។ យើងមានគោលបំណងកសាងលើចំណុចខ្លាំងៗពីគម្រោងដំណាក់កាលទី១ ដោយធ្វើកំណែទម្រង់ដោយទំនុកចិត្តលើចំណុចដែលត្រូវការកែលម្អ និងបន្តសកម្មភាពដែលផ្តោតលើសុខុមាលភាពរបស់មនុស្សគ្រប់គ្នាដែលពាក់ព័ន្ធ។ សូមរីករាយជាមួយចំណុចចាប់ផ្តើមថ្មីនេះជាមួយគ្នា!

**ម៉ាស៊ឹកូ យូកា | នាយកប្រចាំប្រទេស អង្គការ STEP**

## ចំណាប់អារម្មណ៍ អគ្គលេខាធិការរង




ខ្ញុំបាទមានកិត្តិយសណាស់ដែលបានក្លាយជាសមាជិកនៃ គម្រោងអភិវឌ្ឍន៍សុខភាពសិក្សាសម្រាប់កុមារកម្ពុជា (SHCC) - ដំណាក់កាលទី ២ ក្រោមក្របខ័ណ្ឌអន្តរជាតិថ្មីរបស់យើង។ យើងកំពុងផ្តោតការយកចិត្តទុកដាក់លើការរៀបចំកម្មវិធីសិក្សា និងសៀវភៅសិក្សាសុខភាពសិក្សាសម្រាប់កម្រិតមធ្យមសិក្សាបឋមភូមិ នៅតាមវិទ្យាស្ថានគរុកោសល្យ។ គោលដៅធំរបស់យើង គឺពង្រឹងសមត្ថភាពគ្រូឧទ្ទេស តាមរយៈវិធីសាស្ត្រសហការគ្នា។ ខ្ញុំបាទប្តេជ្ញានឹងខិតខំឱ្យអស់ពីសមត្ថភាព ដើម្បីគាំទ្រដល់គម្រោងនេះ ក៏ដូចជាសិក្សារៀនសូត្របន្ថែមពីបទពិសោធន៍ និងជំនាញរបស់គ្រូឧទ្ទេសសុខភាពសិក្សារបស់យើងផងដែរ។

**ថាយ សុខហេង | អគ្គលេខាធិការរងនៃអង្គការ STEP**

## ចំណាប់អារម្មណ៍ មន្ត្រីកម្មវិធី



ក្នុងនាមជាសមាជិកក្រុម ខ្ញុំមានកិត្តិយសក្នុងការបន្តគម្រោងសុខភាពសិក្សា ក្រោមអង្គការថ្មីរបស់យើងគឺ STEP ។ ការផ្លាស់ប្តូរនេះមិនគ្រាន់តែជាការចាប់ផ្តើមថ្មីប៉ុណ្ណោះទេ ប៉ុន្តែគឺជាការប្តេជ្ញាចិត្តជាថ្មីចំពោះសុខុមាលភាពរបស់កុមារកម្ពុជា និងនិរន្តភាពក្នុងការគាំទ្រកម្មវិធីសុខភាពសិក្សា។

ការបង្កើតសម្ភារៈសិក្សាប្រកបដោយគុណភាពខ្ពស់និងខ្លឹមសារ គឺជាទំនួលខុសត្រូវនិងចំណង់ចំណូលចិត្តរបស់ខ្ញុំ។ ខ្ញុំនឹងបន្តចូលរួមឱ្យអស់ពីសមត្ថភាពរបស់ខ្ញុំសហការជាមួយក្រុមការងារដ៏ល្អរបស់អង្គការ និងសមាជិកគ្រួសាររបស់ STEP ទាំងអស់ដើម្បីកសាងអនាគតប្រកបដោយសុខភាពល្អ។

**លី កល្យាណ | មន្ត្រីកម្មវិធី អង្គការ STEP**

## ចំណាប់អារម្មណ៍ មន្ត្រីកម្មវិធី



ខ្ញុំជឿជាក់ថា សុខភាពសំខាន់ណាស់សម្រាប់មនុស្សគ្រប់រូប។ តាមរយៈសកម្មភាពតូចៗប្រចាំថ្ងៃដូចជា សកម្មភាពរាងកាយ របបអាហារត្រឹមត្រូវ និងអនាម័យ ទាំងនេះអាចបង្កើតការផ្លាស់ប្តូរដ៏ធំបាន។ សូមធ្វើឲ្យសុខុមាលភាពក្លាយជាអាទិភាព សម្រាប់អនាគតភ្លឺស្វាង និងមានសុខភាពល្អ តាមរយៈគម្រោង SHCC ដំណាក់កាលទី២ ដោយលើកកម្ពស់ទម្លាប់ឱ្យមានសុខភាពល្អ បរិយាកាសសុវត្ថិភាព និងការចូលរួមសកម្មពីសិស្សានុសិស្ស បុគ្គលិក និងសហគមន៍។

**គឹម ប៊ុណ្ណាភារ | មន្ត្រីកម្មវិធី អង្គការ STEP**

# NEW SLETTER

School Health Training and Ecohealth Promotion Foundation

VOLUME 1 | 03 March, 2026

## What is NGO STEP?




**School Health Training and Ecohealth Promotion Foundation** is an International NGO, which Head Quarters is in Japan. We call it NGO STEP, taking the initials of the organization's name.

The mission of NGO STEP is to promote the introduction of school health in Cambodia and the health of children. In particular, we will promote school health projects with an educational approach, aiming to make health education a routine part of the school day.

We have taken over the School Health Development Project for all Cambodian Children (SHCC) from Tokyo Gakugei University and will proceed with it as Phase 2.

## Message from the Chairperson



I am Takashi Asakura, Chairperson of the School Health Training and Ecohealth Promotion Foundation (STEP).

I believe that improving Cambodian society requires an approach that is neither purely top-down nor purely bottom-up, but rather a middle-up and middle-down approach. In the field of school health education, teacher education colleges can serve as core institutions that propose school health education and teacher training policies to the government, while at the same time dispatching trained teachers to local schools. Through this process, the health of children and communities across the country can be improved. I believe that strengthening this “middle layer” is the key to building a healthier nation, society, and population in Cambodia.

**Prof. Dr. Asakura Takashi**
**Chairperson, School Health Training and Ecohealth Promotion Foundation (STEP)**

## Our Organization

NGO STEP is promoted mainly by the Head Office (Tokyo Gakugei University Office) and the Cambodia Office, with the cooperation of faculty members from other universities who have specialist knowledge and skills. Our main project is SHCC project and supported by The Nippon Foundation.



## 1 Development of School Health Textbook for Teacher Education Colleges (TEC)



We are developing a school health textbook designed to help student teachers at teacher education colleges acquire the knowledge and skills necessary to teach school health to children.
The textbook covers not only practical knowledge for teaching children, but also provides comprehensive content that allows student teachers to study school health as an academic discipline.

## 2 Introduction of School Health Teaching Practicum in the Primary School Education Program at TEC



In Cambodian primary schools, school health, which has been newly introduced as a subject, is mainly taught by homeroom teachers.
To ensure that student teachers graduating from the primary school education program at teacher education colleges can teach school health smoothly in actual school settings, we are working to incorporate school health into teaching practicums.

## 3 Establishment of the School Health Course in Lower Secondary School Teacher Training Program at TEC



STEP aims to establish Cambodia's first specialized school health course within the lower secondary school education program.
In addition to developing the syllabus, textbooks, and teaching materials needed to acquire specialized knowledge, we will also provide student teachers with practical instruction, such as the management of school health rooms, through school health lecturers.

## 4 School Health Lecturer Training



We train school health lecturers at teacher education colleges in Cambodia who are responsible for teaching school health classes. We regularly conduct comprehensive school health training sessions covering topics such as the content of school health textbooks, health education teaching methodologies, and the management of school health rooms. In addition, we also organize lesson study to improve the quality of instruction.

# Voices that move NGO STEP forward

## Message from Country Director



STEP is a new organization, but its members are not new. I believe we can continue to demonstrate the same excellent teamwork as before. We aim to build on the strengths of Phase 1, boldly reform areas that need change, and pursue activities focused on the well being of everyone involved. Let's enjoy this new beginning!

**Masuko Yuka | Country Director, NGO STEP**

## Message from  Deputy Secretary General




It is an honor to be a member of the SHCC – Phase II Project under our new international framework. We are focusing our expertise on creating modern school health syllabi and textbooks, specifically for lower secondary education at Teacher Education Colleges. Our goal is to build the capacity of lecturers through a collaborative approach. I look forward to giving my best to support this community and learning from the expertise of our school health lecturers.

**Thay Sokheng | Deputy Secretary General, NGO STEP**

## Message from Program Officer



As a team member, I am honored to continue the School Health Project under our new organization, STEP. This transition marks not just a new beginning, but a renewed commitment to the well-being of Cambodian children and more sustainable in supporting school health program.
Creating high-quality, meaningful learning materials is both a responsibility and a passion for me. I will continue to contribute my best in working together with the organization's excellent team and all members of the STEP family to build a healthy future.

**Ly Kalyan | Program Officer, NGO STEP**

## Message from Program Officer



I believe that health is essential for everyone. Small daily actions—like staying active, eating well, and practicing hygiene—can make a big difference. Let's make wellness a priority for a brighter, healthier future through SHCC project Phase 2 by promoting healthy habits, safe environments, and active participation from students, staff, and communities.

**Bunnakar Kim | Program Officer, NGO STEP**